ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

សាលក្រមមុនអង្គសេចក្តី
លេខ ១០០ "ក្រ៦ស"
ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២៣
សំណុំរឿងព្រហ្មទណ្ឌលេខ ២៦៨៦
ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២៣
សំណុំរឿងស៊ើបសួរលេខ ២០០៦
ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២៣
សំណុំរឿងជំនុំជម្រះលេខ ៤៣៦៦
ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៣

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ភ្នំពេញ ថ្ងៃទី 02 ខែ 02 ឆ្នាំ 2024
ក្រឡាបញ្ជី

## អានដោយនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជាសាធារណៈនៅថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២៣ វេលាម៉ោង ២ រសៀល នៅសាលសវនាការទី៧ ដោយមានសមាសភាព៖

**ក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted] អនុប្រធានសាលាដំបូងរាជធានីភ្នំពេញ ជាប្រធានក្រុមប្រឹក្សា

លោក ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ជាចៅក្រមប្រឹក្សា

លោក ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ជាចៅក្រមប្រឹក្សា

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ២៦៨៦ ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២៣ ដែលមានជនជាប់ចោទ៖

[redacted] ១-ឈ្មោះ [redacted] ច័ន្ទសុផល ភេទប្រុស អាយុ ៤២ ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើតនៅសង្កាត់ [redacted] ក្រុងភ្នំពេញ អាសយដ្ឋាននៅផ្ទះគ្មានលេខ ផ្លូវលំ ភូមិត្រពាំងខ្លារ ឃុំផក់ឈើនាង ស្រុកអង្គស្នួល ខេត្តកណ្ដាល ប្រពន្ធឈ្មោះ [redacted] សាន មានកូន ២ នាក់ ឪពុកឈ្មោះ [redacted] ស៊ីម៉ុង "ស" ម្ដាយឈ្មោះ [redacted] ហាន "រ" ទោសពីមុនគ្មាន។

-ឃុំខ្លួននៅពន្ធនាគាររាជធានីភ្នំពេញ តាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៤០៣៤ "ឈ១" ដ.ឃ.ដ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២៣។

-មេធាវីការពារក្តីលោកមេធាវី [redacted]

២-ឈ្មោះ [redacted] សំអូន ហៅ ព្រះគោ ភេទប្រុស អាយុ ៣៦ ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើតនៅភូមិ [redacted] ខេត្តកំពង់ចាម អាសយដ្ឋាននៅដីឡូត៍លេខ៥៦ ផ្លូវលេខ២១៧ ភូមិសំបួរ សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ ប្រពន្ធឈ្មោះ [redacted] ស្រីម៉ៅ មានកូន ២ នាក់ ឪពុក

Scanned with CamScanner

ឈ្មោះ [redacted] ខ្លួត "ស" ម្ដាយឈ្មោះ [redacted] ម៉ីយ "ស" ទោសពីមុនគ្មាន។

-ឃុំខ្លួននៅពន្ធនាគាររាជធានីភ្នំពេញ តាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៩០៣៧ "ឈ១" ង.ឃ.ង ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២៣។

-មេធាវីការពារក្ដីលោកមេធាវី [redacted]។

៣-ឈ្មោះ [redacted] ហុង ភេទប្រុស កើតនៅថ្ងៃទី០១-១២-១៩៨៣ ជនជាតិខ្មែរ ទីកន្លែងកំណើតនៅភូមិ [redacted] ខេត្តបាត់ដំបង អាសយដ្ឋាននៅភូមិអូរស្មាច់ ឃុំអូរស្មាច់ ស្រុកសំរោង ខេត្តឧត្ដរមានជ័យ ប្រពន្ធឈ្មោះ [redacted] សាយី មានកូន ៣ នាក់ ឪពុកឈ្មោះ [redacted] ផាង "ស" ម្ដាយឈ្មោះ [redacted] លន់ "ស" ទោសពីមុនគ្មាន។

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
ភ្នំពេញ ថ្ងៃទី 02 ខែ 02 ឆ្នាំ 2024
ក្រឡាបញ្ជី

-នៅក្រៅឃុំ។

-មេធាវីការពារក្ដីលោកមេធាវី [redacted]

-ជាប់ចោទពីបទ **រក្សាទុកដោយខុសច្បាប់នូវអាវុធជាតិផ្ទុះ (សង្ស័យជាសារធាតុអ៊ុយរ៉ាញ៉ូមក្នុងគោលបំណងលក់ដូរ)** តាមបញ្ញត្តិមាត្រា២៦ នៃច្បាប់ស្ដីពីការហាមឃាត់អាវុធគីមី អាវុធនុយក្លេអ៊ែរ អាវុធជីវសាស្ត្រ និងអាវុធវិទ្យុសកម្ម ប្រព្រឹត្តនៅខេត្តកំពង់ស្ពឺ និងនៅរាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០២២ និងឆ្នាំ២០២៣ តាមដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ៥៤២៣ "ឈ១" ង.ង ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងរាជធានីភ្នំពេញ។

៤-ឈ្មោះ [redacted] ពៅ ភេទប្រុស អាយុ ៤៣ ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើត [redacted] ខេត្តព្រៃវែង អាសយដ្ឋាននៅផ្ទះលេខ៧០ ផ្លូវលេខ១១ ភូមិពាមា ឃុំអំពិលក្រៅ ស្រុកស៊ីធរកណ្ដាល ខេត្តព្រៃវែង ប្រពន្ធឈ្មោះ [redacted] ភារី មានកូន ៣ នាក់ ឪពុកឈ្មោះ [redacted] ប៊ុនថេន "ស" ម្ដាយឈ្មោះ [redacted] កាន "ស" ទោសពីមុនគ្មាន។

-ឃុំខ្លួននៅមណ្ឌលអប់រំកែប្រែទី១ តាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៩០៣៦ "ឈ១" ង.ឃ.ង ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២៣។

-មេធាវីការពារក្ដីលោកមេធាវី [redacted]។

៥-ឈ្មោះ [redacted] សុខម៉េង ភេទប្រុស អាយុ ៣៨ ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើត [redacted] ខេត្តកំពង់ចាម អាសយដ្ឋាននៅភូមិព្រែកកក់ ឃុំព្រែកចាក់ ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម នៅលីវ ឪពុកឈ្មោះ [redacted] សុខវ៉េត "ស" ម្ដាយឈ្មោះ [redacted] បូរ៉ា "រ" ទោសពីមុនគ្មាន។

-ឃុំខ្លួននៅមណ្ឌលអប់រំកែប្រែទី១ តាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៩០៣៥ "ឈ១" ង.ឃ.ង ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២៣។

-មេធាវីការពារក្ដីលោកមេធាវី [redacted]

៦-ឈ្មោះ [redacted] សុគន់ ភេទប្រុស អាយុ ៤៣ ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើត [redacted]

Scanned with CamScanner

[redacted] ខេត្តបាត់ដំបង អាសយដ្ឋាននៅភូមិបឹងតូច ឃុំសឿ ស្រុកមង្គលបូរី ខេត្តបាត់ដំបង ប្រពន្ធឈ្មោះ [redacted] សុខនឿន មានកូន ១ នាក់ ឪពុកឈ្មោះ [redacted] សុវណ្ណវិជ័យ "រ" ម្តាយឈ្មោះ [redacted] ប៊ុនធី "ស" ទោសពីមុនគ្មាន។

-ឃុំខ្លួននៅមណ្ឌលអប់រំកែប្រែទី១ តាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៤៨១៨ "ឈ១" ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២៣។

-មេធាវីការពារក្តីលោកមេធាវី [redacted]

៧-ឈ្មោះ [redacted] ចន្រ្ទា ភេទប្រុស អាយុ ៣៨ ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើត [redacted] ខណ្ឌទួលគោក រាជធានីភ្នំពេញ អាសយដ្ឋាននៅផ្ទះលេខ៣៤E0 ផ្លូវព្រះសីហនុ ក្រុម២៦ មណ្ឌល២ ភូមិ៣ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] ឡា ម្តាយឈ្មោះ [redacted] ស ទោសពីមុន គ្មាន។

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
ភ្នំពេញ ថ្ងៃទី......ខែ 02 ឆ្នាំ 2024
ក្រឡាបញ្ជី

-នៅក្រៅឃុំ។

-មេធាវីការពារក្តីលោកមេធាវី [redacted]។

-ជាប់ចោទពីបទ **សមគំនិតក្នុងអំពើរក្សាទុកដោយខុសច្បាប់នូវអាវុធគីមី (សង្ស័យជាសារធាតុអ៊ុយរ៉ាញ៉ូម ក្នុងគោលបំណងលក់ដូរ)** តាមបញ្ញត្តិមាត្រា២៩ នៃក្រមព្រហ្មទណ្ឌ និង [redacted]២៦ នៃច្បាប់ស្តីពី ការហាមឃាត់អាវុធគីមី អាវុធនុយក្លេអ៊ែរ អាវុធជីវសាស្រ្ត និងអាវុធវិទ្យុសកម្ម ប្រព្រឹត្តនៅខេត្តកំពង់ស្ពឺ និងនៅរាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០២២ និងឆ្នាំ២០២៣ តាមដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ៥៤២៣ "ឈ១" ង.ង ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងរាជធានីភ្នំពេញ។

## <u>អង្គហេតុនៃរឿងមានដូចតទៅ</u>

-កាលពីថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២៣ ក្រុមព័ត៌មានទាន់ហេតុការណ៍ ជាមួយជនបរទេស នៃអគ្គស្នងការនគរបាលជាតិ បានទទួលព័ត៌មានពីស្ថានទូតរុស្ស៊ីប្រចាំព្រះរាជាណាចក្រកម្ពុជា ថាមានឈ្មោះ [redacted] រៅ និងឈ្មោះ [redacted] សុខម៉េង បានយករូបភាពវត្ថុម្យ៉ាងដែលសង្ស័យជាសារធាតុគីមីពុល (សារធាតុអ៊ុយរ៉ាញ៉ូម) ដើម្បីលក់ឱ្យរដ្ឋាភិបាលរុស្ស៊ី សម្រាប់ផលិតនុយក្លេអ៊ែរ បន្ទាប់ពីបានទទួលព័ត៌មាននេះកម្លាំងនាយកដ្ឋានចារកម្ម នៃអគ្គស្នងការនគរបាលជាតិ បានឃាត់ខ្លួនជនជាប់ចោទឈ្មោះ [redacted] រៅ និងឈ្មោះ [redacted] សុខម៉េង និងបានបន្តចាប់ឃាត់ខ្លួនជនជាប់ចោទឈ្មោះ [redacted] សំអូន , ជនជាប់ចោទឈ្មោះ [redacted] ច័ន្ទសុផល និងជនជាប់ចោទឈ្មោះ [redacted] សុគង់ និងដកហូតនូវ ដបជាលោហៈពណ៌ឈាមជ្រូក ទម្ងន់ប្រហែល ១,២ គីឡូក្រាម ប្រគល់ជូនអគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិអាវុធគីមីដើម្បីរក្សាទុក។

-តាមលទ្ធផលកោសលវិច័យលេខ ៣៤៨ ស.ណ/២០២៣ ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២៣ របស់អគ្គលេខាធិកាដ្ឋាន នៃអាជ្ញាធរជាតិអាវុធគីមី បញ្ជាក់ថា ផ្អែកតាមរូបរាងនៃវត្ថុតាងសង្ស័យ អាចសន្និដ្ឋានបានថា វត្ថុតាងខាងលើមានផ្ទុកសារធាតុនុយក្លេអ៊ែរគ្រោះថ្នាក់ប្រភេទ Uranium-235 (U-235)

Scanned with CamScanner

និងមានគ្រោះថ្នាក់១០០% ប៉ុន្តែបច្ចុប្បន្នពុំទាន់អាចធ្វើការស្រាវជ្រាវផ្នែកខាងក្នុងនៃវត្ថុតាងបាន ដោយហេតុទំហំគ្រោះថ្នាក់ធំ និងទាមទារបច្ចេកទេសខ្ពស់ ដូច្នេះអគ្គលេខាធិការដ្ឋាន អាជ្ញាធរជាតិអាវុធគីមី ត្រូវការពេលវេលាក្នុងការសិក្សាស្រាវជ្រាវបន្តទៀត។

-បានឃើញ របាយការណ៍លេខ ៧១៤.២៣ រ.ប.ក ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២៣ របស់នាយកដ្ឋានចារកម្ម នៃអគ្គស្នងការនគរបាលជាតិ។

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ២០២៨ អ.យ.ជ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២៣ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ ៤២២០ អ.យ.ជ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២៣ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
ភ្នំពេញ ថ្ងៃទី 02 ខែ 02 ឆ្នាំ 2024
ក្រឡាបញ្ជី

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] ច័ន្ទសុផល បានឆ្លើយថា ខ្លួនមានមុខរបរបើកហាងយីហោសុខសាន្ត នៅខេត្តកំពង់ស្ពឺ និងបានស្គាល់ឈ្មោះ [redacted] សុគង់ ដែលធ្លាប់ទៅហូបអាហារនៅក្នុងហាងរបស់ខ្លួន ហើយកាលឆ្នាំ២០២២ ឈ្មោះ [redacted] សុគង់ បានបង្ហាញរូបវត្ថុជាមបណោហៈមួយឱ្យខ្លួនមើល ហើយប្រាប់ [redacted] ថាវត្ថុមានតម្លៃ ដោយសារឃើញរូបរាងវត្ថុនោះមានភាពចម្លែក ខ្លួនបានសួរនាំឈ្មោះ [redacted] សុគង់ វត្ថុនោះជារបស់ឈ្មោះ [redacted] ហុង រស់នៅខេត្តបាត់ដំបង ដោយសារចង់បានខ្លួនបានឱ្យឈ្មោះ [redacted] ហុង ជូនទៅទិញយកវត្ថុនោះពីឈ្មោះ [redacted] ហុង ដោយខ្លួនឱ្យតម្លៃ ១,០០០ (មួយពាន់) ដុល្លារអាមេរិក បន្ទាប់មកខ្លួនបានយកទៅរក្សាទុកនៅក្នុងបន្ទប់ដេករបស់ខ្លួន នៅក្នុងអំឡុងពេលនោះខ្លួមបានស្វែងរកអ្នកដែលអាចស្គាល់អត្តសញ្ញាណវត្ថុនោះ ហើយមានគេកំណត់អត្តសញ្ញាណថាជាវត្ថុមានគ្រោះថ្នាក់ ក្រោយមកឈ្មោះ [redacted] ចក្រី បានចុះកិច្ចសន្យាទិញវត្ថុពីខ្លួន តែក្រោយមកបាត់ដំណឹងឈប់ទាក់ទងគ្នាវិញ នៅក្នុងឆ្នាំ២០២២ ដដែលឈ្មោះ [redacted] សំអូន និងគ្នីគ្នាគាត់បានទៅហូបបាយនៅក្នុងហាងរបស់ខ្លួន ហើយខ្លួនបានបង្ហាញរូបវត្ថុនោះឱ្យពួកគេមើល ក្រែងស្គាល់វត្ថុនោះជាអ្វីដើម្បីលក់ បន្ទាប់មកឈ្មោះ [redacted] សំអូន បាននាំឈ្មោះ [redacted] ទៅពិនិត្យមើលវត្ថុនោះដោយផ្ទាល់ភ្នែក ហើយខ្លួនបានសន្យាថា បើលក់បានតម្លៃខ្លួនឱ្យតម្លៃ ១០% ហើយនៅថ្ងៃបន្ទាប់ខ្លួនត្រូវសមត្ថកិច្ចចាប់ឃាត់ខ្លួន និងដកហូតវត្ថុនោះពីខ្លួនតែម្តង។

-ក្នុងរឿងនេះខ្លួនសុំឱ្យតុលាការដោះលែងខ្លួនឱ្យមានសេរីភាពវិញ ព្រោះខ្លួនមានកូនៗតូចនៅក្នុងបន្ទុកកំពុងជួបការលំបាកចំពោះជីវភាពប្រចាំថ្ងៃ។

-ជនជាប់ចោទឈ្មោះ [redacted] សុគង់ បានឆ្លើយថា ខ្លួនបានស្គាល់ឈ្មោះ [redacted] ហុង គាត់រស់នៅខេត្តបាត់ដំបង ហើយកាលពីឆ្នាំ២០២២ គាត់បានថតបង្ហាញវត្ថុចម្លែក មួយ ដោយគាត់បញ្ជាក់ថា គាត់ជីកដីរកឃើញ គាត់ថាអាចជាវត្ថុមានតម្លៃ ហើយឱ្យខ្លួនជួយរកអ្នកទិញ បន្ទាប់មកខ្លួនយករូបនោះទៅបង្ហាញបន្តទៅឈ្មោះ [redacted] ច័ន្ទសុផល ហើយឈ្មោះ [redacted] ច័ន្ទសុផល បានឱ្យខ្លួនជូនទៅទិញ ក្នុងតម្លៃ ១,០០០ ដុល្លារអាមេរិក បន្ទាប់មកឈ្មោះ [redacted] ច័ន្ទសុផល បានទាក់ទងជាមួយខ្លួនណាត់ជួបឈ្មោះ [redacted] ចក្រី ដើម្បីលក់វត្ថុនោះឱ្យឈ្មោះ [redacted] ចក្រី តែការទិញលក់នោះពុំបានសម្រេចទេ ក្រោយមកខ្លួនលែងមាន

Scanned with CamScanner

ទំនាក់អ្វីទាំងអស់រហូតដល់ថ្ងៃសមត្ថកិច្ចចាប់ឃាត់ខ្លួនតែម្តង។

-ក្នុងរឿងនេះខ្លួនសុំឱ្យតុលាការដោះលែងខ្លួនឱ្យមានសេរីភាពវិញ ដោយសារខ្លួនកំពុងមានជំងឺ។

-ជនជាប់ចោទឈ្មោះ [redacted] សំអួន បានឆ្លើយថា កាលពីឆ្នាំ២០២២ ពួកខ្លួនមានគ្នា ៥-៦ នាក់ បានទៅហូបបាយនៅហាងសុខសាន្ត ហើយម្ចាស់ហាងបានយករូបចម្លែកមួយបង្ហាញពួកខ្លួន ដើម្បីឱ្យពួកខ្លួនជួយសម្គាល់វត្ថុនោះជាអ្វី និងប្រកាសលក់វត្ថុនោះបើមានតម្លៃ បន្ទាប់មកខ្លួនបានយករូបនោះទៅបង្ហាញឈ្មោះ [redacted] ពៅ ក្រោយមកឈ្មោះ [redacted] ពៅ បានពឹងខ្លួនឱ្យជូនទៅជួបម្ចាស់វត្ថុនោះដោយផ្ទាល់ ហើយខ្លួនបានជូនទៅជួប ដោយពេលនោះម្ចាស់របស់ និងឈ្មោះ ហ៊ុន ពៅ ជួបគ្នាផ្ទាល់តែពីរនាក់ ចំណែកខ្លួនមិនបានជួបនិយាយជាពួកគេទេ តែម្ចាស់របស់ធ្លាប់ប្រាប់ខ្លួនថា បើរកម៉ូយបានទិញវត្ថុនោះគាត់ឱ្យ ១០% ហើយខ្លួនបានប្រាប់បញ្ហានេះទៅឈ្មោះ [redacted] ពៅ រួចហើយ បន្ទាប់ពីអ្នកទាំងពីរបានជួបគ្នាហើយ នៅថ្ងៃបន្ទាប់ខ្លួនត្រូវសមត្ថកិច្ចចាប់ឃាត់ខ្លួនតែម្តង។

-ក្នុងរឿងនេះខ្លួនសុំឱ្យតុលាការដោះលែងខ្លួនឱ្យមានសេរីភាពវិញ ដោយសារខ្លួនមានជំងឺទឹកនោមផ្អែម និងមានកូនតូចៗនៅក្នុងបន្ទុក។

-ជនជាប់ចោទឈ្មោះ [redacted] ពៅ បានឆ្លើយថា មុនពេលសមត្ថកិច្ចចាប់ឃាត់ខ្លួន ឈ្មោះ [redacted] សំអួន បានយករូបនៅក្នុងទូរស័ព្ទបង្ហាញខ្លួន ហើយខ្លួនកត់សម្គាល់ឃើញថា ជាវត្ថុចម្លែក បន្ទាប់ស្រាប់តែឃើញគេបង្ហោះរូបវត្ថុនោះនៅក្នុងហ្វេសប៊ុក គឺគណនីឈ្មោះ "លក់វត្ថុអច្ឆរិយៈ" ដោយខ្លះបញ្ជាក់នៅក្នុងនោះថា វត្ថុនោះមានតម្លៃរហូតដល់ ៥០០ លានដុល្លារអាមេរិក ហើយប្រទេសរុស្ស៊ី ជាអ្នកទិញ ទើបខ្លួនឱ្យឈ្មោះ [redacted] សំអួន ជូនខ្លួនទៅជួបម្ចាស់របស់ និងបានសុំមើលវត្ថុនោះដោយផ្ទាល់ បន្ទាប់មកខ្លួនបានទូរស័ព្ទទាក់ទងហៅឈ្មោះ [redacted] សុខម៉េង ដែលគាត់ចេះភាសាអង់គ្លេស ដើម្បីឱ្យជូនខ្លួនទៅស្ថានទូតរុស្ស៊ី ដើម្បីទំនាក់ទំនងលក់ វត្ថុនោះ នៅថ្ងៃបន្ទាប់ខ្លួន និងឈ្មោះ [redacted] សុខម៉េង បានទៅស្ថានទូតរុស្ស៊ី និងបានជួបមន្ត្រីស្ថានទូត ហើយបានយករូបវត្ថុនោះបង្ហាញគោលបំណងដើម្បីលក់វត្ថុនោះ ហើយត្រូវសមត្ថកិច្ចចាប់ឃាត់ខ្លួនតែម្តង។

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
...ពេញ ថ្ងៃទី 02 ខែ 02 ឆ្នាំ 2024
ក្រឡាបញ្ជី

-ក្នុងរឿងនេះខ្លួនសុំឱ្យតុលាការដោះលែងខ្លួនឱ្យមានសេរីភាពវិញ ដោយសារខ្លួនកំពុងមានជំងឺ។

-ជនជាប់ចោទឈ្មោះ [redacted] សុខម៉េង បានឆ្លើយថា ខ្លួនចេះភាសាអង់គ្លេសបន្តិចបន្តួចអាចនិយាយស្តាប់បានពាក្យស្រាលៗប៉ុណ្ណោះ មុនពេលសមត្ថកិច្ចចាប់ឃាត់ខ្លួនឈ្មោះ [redacted] ពៅ បានទូរស័ព្ទណាត់ឱ្យខ្លួនជូនគាត់ដើម្បីបកប្រែភាសាអង់គ្លេស ដោយពុំដឹងថាបកប្រែអំពីរឿងអ្វីទេ នៅថ្ងៃស្អែកបន្ទាប់ឈ្មោះ [redacted] បាននាំខ្លួនទៅស្ថានទូតរុស្ស៊ី ពេលទៅដល់ខ្លួនបាននិយាយតាមការស្នើរបស់ឈ្មោះ [redacted] ពៅ ដើម្បីសុំជួបមន្ត្រីនៅក្នុងស្ថានទូត ហើយគេបានណែនាំឱ្យទៅច្រកចូលមួយទៀត ពេលទៅដល់ទីនោះមន្ត្រីស្ថានទូត ចេះនិយាយភាសាខ្មែរ ហើយឈ្មោះ [redacted] ពៅ បាននិយាយដោយផ្ទាល់ជាមួយមន្ត្រីនោះ បន្ទាប់មកគេឱ្យនៅរង់ចាំសិន មួយសន្ទុះក្រោយត្រូវសមត្ថកិច្ចចាប់ឃាត់ខ្លួនតែម្តង។

-ក្នុងរឿងនេះខ្លួនសុំឱ្យតុលាការដោះលែងខ្លួនឱ្យមានសេរីភាពវិញ ដោយសារខ្លួនមានម្តាយចាស់ជរា ហើយមានតែខ្លួនម្នាក់គត់ដែលនៅជួយមើលថែរក្សាចំពោះគាត់។

## សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា ជនជាប់ចោទបានស្នើសុំឱ្យដោះលែងឱ្យនៅក្រៅឃុំ

Scanned with CamScanner

នាពេលសវនាការ ដូចនេះគប្បីតុលាការពិចារណាសម្រេចពីបញ្ហានេះសិន តាមបញ្ញត្តិមាត្រា៣០៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

## សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារជនជាប់ចោទ

-មេធាវីការពារជនជាប់ចោទបានសន្និដ្ឋានការពារថា តាមលទ្ធផលកោសលវិច្ច័យ របស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិអាវុធគីមី ស្ថិតនៅក្នុងវិមតិសង្ស័យនៅឡើយ ហេតុនេះសូមតុលាការពិចារណាសម្រេចដោះលែងជនជាប់ចោទឱ្យមានសេរីភាព ស្របតាមមាត្រា៣៨ នៃរដ្ឋធម្មនុញ្ញ និងមាត្រា៣៥១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

## សំដីចុងក្រោយរបស់ជនជាប់ចោទ

-ជនជាប់ចោទឈ្មោះ [redacted] ច័ន្ទសុផល , ជនជាប់ចោទឈ្មោះ [redacted] សុគង់ , ជនជាប់ចោទឈ្មោះ [redacted] ពៅ , ជនជាប់ចោទឈ្មោះ [redacted] សំអូន និងជនជាប់ចោទឈ្មោះ [redacted] សុខម៉េង បាននិយាយសំដីចុងក្រោយបង្អស់ថា សូមតុលាការមេត្តាសម្រេចដោះលែងខ្លួនឱ្យមានសេរីភាព។

បានចំលងត្រឹមត្រូវតាមច្បាប់ដើម
ភ្នំពេញ ថ្ងៃទី 02 ខែ 02 ឆ្នាំ 2024
ក្រឡាបញ្ជី
[redacted]

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ
-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ
-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារជនជាប់ចោទ
-ក្រោយពីបានស្តាប់ជនជាប់ចោទនិយាយសំដីចុងក្រោយ
-ក្រោយពីបានពិនិត្យលើឯកសារ ភស្តុតាងនានា
-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## សំអាងហេតុ

១-ជនជាប់ចោទ [redacted] ច័ន្ទសុផល , ជនជាប់ចោទឈ្មោះ [redacted] សំអូន ហៅ ព្រះគោ (ហៀសប៊ុក ឈ្មោះ ព្រះគោ) និងជនជាប់ចោទឈ្មោះ [redacted] ហុង ត្រូវបានចោទប្រកាន់ពីបទ រក្សាទុកដោយចេតនានូវអាវុធគីមី (សង្ស័យជាសារធាតុអ៊ីយ៉ាញ៉ូម ក្នុងគោលបំណងលក់ដូរ) តាមបញ្ញត្តិមាត្រា២៦ នៃច្បាប់ស្តីពីការហាមឃាត់អាវុធគីមី អាវុធនុយក្លេអ៊ែរ អាវុធជីវសាស្ត្រ និងអាវុធវិទ្យុសកម្ម ប្រព្រឹត្តនៅខេត្តកំពង់ស្ពឺ និងនៅរាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០២២ និងឆ្នាំ២០២៣ ចំណែកជនជាប់ចោទឈ្មោះ [redacted] ពៅ ជនជាប់ចោទឈ្មោះ [redacted] សុខម៉េង និងជនជាប់ចោទឈ្មោះ [redacted] ចក្រី ត្រូវបានចោទប្រកាន់ពីបទ សមគំនិតក្នុងអំពើរក្សាទុកដោយចេតនានូវអាវុធគីមី (សង្ស័យជាសារធាតុអ៊ីយ៉ាញ៉ូម ក្នុងគោលបំណងលក់ដូរ) តាមបញ្ញត្តិមាត្រា២៩ នៃក្រមព្រហ្មទណ្ឌ និងបញ្ញត្តិមាត្រា២៦ នៃច្បាប់ស្តីពីការហាមឃាត់អាវុធគីមី អាវុធនុយក្លេអ៊ែរ អាវុធជីវសាស្ត្រ និងអាវុធវិទ្យុសកម្ម ប្រព្រឹត្តនៅខេត្តកំពង់ស្ពឺ និងនៅរាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០២២ និងឆ្នាំ២០២៣។

២-តាមលិខិតលេខ ៣៤៨ /២០២៣/ស.ណ ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២៣ របស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិអាវុធគីមី បញ្ជាក់ថា ផ្អែកតាមរូបរាងនៃវត្ថុសង្ស័យ (Physical Description of

Scanned with CamScanner

the evidence) យើងអាចសន្និដ្ឋានបានថា វត្ថុខាងលើមានផ្ទុកសារធាតុនុយក្លេអ៊ែរគ្រោះថ្នាក់ប្រភេទ Uranium-235 (U-235) និងមានគ្រោះថ្នាក់ ១០០% ប៉ុន្តែបច្ចុប្បន្នយើងពុំទាន់អាចធ្វើការស្រាវជ្រាវផ្នែកខាងក្នុងនៃវត្ថុតាងបាន ដោយហេតុទំហំគ្រោះថ្នាក់ធំ និងទាមទារបច្ចេកទេសខ្ពស់ ដូច្នេះអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិអាវុធគីមី ត្រូវការពេលវេលាក្នុងការសិក្សាស្រាវជ្រាវបន្ត។

៣-ជនជាប់ចោទឈ្មោះ [redacted] ច័ន្ទសុផល , ជនជាប់ចោទឈ្មោះ [redacted] សុគង់ , ជនជាប់ចោទឈ្មោះ [redacted] ពៅ , ជនជាប់ចោទឈ្មោះ [redacted] សំអូន និងជនជាប់ចោទឈ្មោះ [redacted] សុខម៉េង បានឃុំខ្លួនជាបណ្តោះអាសន្ន ដើម្បីរង់ចាំតុលាការសម្រេចផ្តន្ទាទោសចំពោះអំពើដែលជនជាប់ចោទបានប្រព្រឹត្ត ប៉ុន្តែផ្អែកតាមលិខិតបញ្ជាក់របស់អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិអាវុធគីមី បានបញ្ជាក់ថាត្រូវការពេលវេលាក្នុងការសិក្សាស្រាវជ្រាវបន្ត នូវវត្ថុតាងសង្ស័យដែលជាធាតុសម្ភារៈនៃបទល្មើសនេះ ដូចនេះតុលាការមិនអាចពិចារណាសម្រេចផ្តន្ទាទោសជនជាប់ចោទ តាមការចោទប្រកាន់បាននៅឡើយទេ ព្រោះវត្ថុតាងសង្ស័យជាធាតុសម្ភារៈនៃបទល្មើសនេះមិនត្រូវបានបញ្ជាក់ដោយអ្នកជំនាញថា ជាអាវុធគីមី អាវុធនុយក្លេអ៊ែរ អាវុធជីវសាស្ត្រ អាវុធវិទ្យុសកម្ម និងជាសារធាតុគីមីដែលទាក់ទងនឹងការផលិតអាវុធទាំងនេះនៅឡើយ។

៤-ជនជាប់ចោទឈ្មោះ [redacted] ច័ន្ទសុផល , ជនជាប់ចោទឈ្មោះ [redacted] សុគង់ , ជនជាប់ចោទឈ្មោះ [redacted] ពៅ , ជនជាប់ចោទឈ្មោះ [redacted] សំអូន និងជនជាប់ចោទឈ្មោះ [redacted] សុខម៉េង សុំឱ្យដោះលែងឱ្យមានសេរីភាពវិញ មានមូលហេតុសមស្របទៅនឹងកម្មវត្ថុផ្ទាល់ខ្លួនរបស់ជនជាប់ចោទ និងសមស្របទៅនឹងចំពោះគោលការណ៍នៃការឃុំខ្លួនបណ្តោះអាសន្ន តាមបញ្ញត្តិមាត្រា២០៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ហេតុនេះគប្បីសម្រេចដោះលែងជនជាប់ចោទឱ្យមានសេរីភាព តាមមាត្រា៣០៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ និងដើម្បីធានាវត្តមានរបស់ជនជាប់ចោទឱ្យបង្ហាញខ្លួននៅចំពោះមុខតុលាការនាពេលខាងមុខបន្ត គប្បីសម្រេចដាក់ឱ្យជនជាប់ចោទគោរពកាតព្វកិច្ចមួយចំនួន នៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ។

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
ភ្នំពេញ ថ្ងៃទី 02 ខែ 02 ឆ្នាំ 2024
ក្រឡាបញ្ជី

## ហេតុដូច្នេះសម្រេច

១-ទទួលពាក្យសុំដោះលែងឱ្យនៅក្រៅឃុំរបស់ជនជាប់ចោទឈ្មោះ [redacted] **ច័ន្ទសុផល** ភេទប្រុស អាយុ ៤២ ឆ្នាំ ជនជាតិខ្មែរ , ជនជាប់ចោទឈ្មោះ [redacted] **សំអូន** ហៅ **ព្រះគោ** (ហៀសប៉ិកឈ្មោះ ព្រះ [redacted] ភេទប្រុស អាយុ ៣៦ ឆ្នាំ ជនជាតិខ្មែរ , ជនជាប់ចោទឈ្មោះ [redacted] **ពៅ** ភេទប្រុស អាយុ ៤៣ ឆ្នាំ ជនជាតិខ្មែរ , ជនជាប់ចោទឈ្មោះ [redacted] **សុខម៉េង** ភេទប្រុស អាយុ ៣៨ ឆ្នាំ ជនជាតិខ្មែរ និងជនជាប់ចោទឈ្មោះ [redacted] **សុគង់** ភេទប្រុស អាយុ ៤៣ ឆ្នាំ ជនជាតិខ្មែរ ទុកជាត្រឹមត្រូវតាមបញ្ញត្តិមាត្រា៣០៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

Scanned with CamScanner

២-បង្គាប់ឱ្យដោះលែងជនជាប់ចោទឈ្មោះ [redacted] ច័ន្ទសុផល ភេទប្រុស អាយុ ៤២ ដែលបានឃុំខ្លួននៅពន្ធនាគាររាជធានីភ្នំពេញ (PJ) តាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៤០៣៤ "ឈ១" ដ.ឃ.ដ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២៣ , ជនជាប់ចោទឈ្មោះ [redacted] សំអូន ហៅ ព្រះគោ (ហៀសប៊ុកឈ្មោះ ព្រះគោ) ភេទប្រុស អាយុ ៣៦ ឆ្នាំ ដែលបានឃុំខ្លួននៅពន្ធនាគាររាជធានីភ្នំពេញ (PJ) តាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៤០៣៧ "ឈ១" ដ.ឃ.ដ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២៣ ,ជនជាប់ចោទឈ្មោះ [redacted] ពៅ ភេទប្រុស អាយុ ៤៣ ឆ្នាំ ដែលបានឃុំខ្លួននៅមណ្ឌលអប់រំកែប្រែទី១ (ម១) តាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៤០"ឈ១" ដ.ឃ.ដ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២៣ , ជនជាប់ចោទឈ្មោះ [redacted] សុខម៉េង ភេទប្រុស អាយុ ៣៨ ឆ្នាំ ដែលបានឃុំខ្លួននៅមណ្ឌលអប់រំកែប្រែទី១ (ម១) តាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៤០៣៥ "ឈ១" ដ.ឃ.ដ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២៣ និងជនជាប់ចោទឈ្មោះ [redacted] សុគង់ ភេទប្រុស អាយុ ៤៣ ឆ្នាំ ដែលបានឃុំខ្លួននៅមណ្ឌលអប់រំកែប្រែទី១ (ម១) តាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៤៨១៨ "ឈ១" ដ.ឃ.ដ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២៣ ជាបណ្ដោះអាសន្នមុនអង្គសេចក្ដី ប្រសិនបើឈ្មោះខាងលើនេះមិនត្រូវបានឃុំខ្លួនពីបទល្មើសផ្សេងទៀតទេ។

៣-បង្គាប់ឱ្យឈ្មោះ [redacted] ច័ន្ទសុផល , ឈ្មោះ [redacted] សំអូន ហៅ ព្រះគោ (ហៀសប៊ុកឈ្មោះ ព្រះគោ) , ឈ្មោះ [redacted] ពៅ , ឈ្មោះ [redacted] សុខម៉េង និងឈ្មោះ [redacted] សុគង់ ត្រូវអនុវត្តវិធាននៅក្រោមការត្រួតពិនិត្យដូចខាងក្រោម៖

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
...ពេញ ថ្ងៃទី......... ខែ 02 ឆ្នាំ 2024
ក្រឡាបញ្ជី

ក-មិនអនុញ្ញាតឱ្យផ្លាស់ប្ដូរលំនៅឋានដែលធ្លាប់បានប្រកាសនៅចំពោះមុខចៅក្រមស៊ើបសួរ

ខ-មិនអនុញ្ញាតឱ្យចាកចេញពីព្រះរាជាណាចក្រកម្ពុជា

គ-ត្រូវចូលមកឆ្លើយបំភ្លឺនៅពេលមានដីកាកោះហៅពីតុលាការ។

-សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២៣ ចំពោះមុខជនជាប់ចោទ [redacted] ផល , ជនជាប់ចោទឈ្មោះ [redacted] សំអូន ហៅ ព្រះគោ (ហៀសប៊ុកឈ្មោះ ព្រះគោ) , ជនជាប់ចោទឈ្មោះ [redacted] ពៅ , ជនជាប់ចោទឈ្មោះ [redacted] សុខម៉េង និងជនជាប់ចោទឈ្មោះ [redacted] សុគង់ ប្រកាសជាសាធារណៈនៅថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២៣។

-គូភាគីមានសិទ្ធិប្ដឹងឧទ្ធរណ៍ក្នុងរយៈពេលដែលច្បាប់កំណត់។

| ក្រឡាបញ្ជីសវនាការ | ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|---|

ហត្ថលេខា និងត្រា [redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ថ្ងៃពុធ ១៥កើត ខែមិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២៣
ក្រឡាបញ្ជី
[redacted]

បានឃើញ
ប្រធានក្រុមប្រឹក្សាជំនុំជម្រះ
[redacted]

Scanned with CamScanner